របាយការណ៍វឌ្ឍនភាពស្តីពីគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨

"ឈានទៅបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈ"

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១

ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦

បង្ហាញដោយ**វេជ្ជ. ទេព ណារ៉ុង** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

មាតិកា

១ បច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា

២ ស្ថានភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៦


៣ បញ្ហាប្រឈម

៤ ទិសដៅអនុវត្តបន្ត

១

បច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍

១. ស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា
Summary of the AIDS Epidemic in Cambodia



- ករណីឆ្លងថ្មីប្រមាណ ៩៥៨នាក់
- ករណីស្លាប់ប្រមាណ ៩៧៤នាក់

Cambodia HIV Prevalence

0.5%


Adult population aged 15-49 (AEM 2025)





Source: 2025 HIV estimates based on AEM and spectrum modelling estimates

២. និន្នាការនៃមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា

HIV estimates trend







៣. ការប៉ាន់ប្រមាណចំនួនក្រុមប្រជាជនគន្លឹះឆ្នាំ២០២៤ និង២០២៥

KP size estimates used in AEM

KPs	2024 modelling	2025 modelling
FEW	52,400 (IBBS 2022- 1.23% of adult female)	Same
PWID	3,300 (0.08% of adult male)	Same
MSM	119,200 (2.7% adult male)	120,900 (2.7% adult male)
MSM1	89,400 (75% of total MSM)	90,700 (75% of total MSM)
MSM2	29,800 (25% of total MSM)	30,200 (25% of total MSM)
MSW	7,200 (8% of MSM1 as IBBS 2023	7,300 (8% of MSM1 as IBBS 2023)
TG	15,660 PSE as part of IBBS 2023	22,000 (adjusted to match with the programme reach)


ប៉ាន់ប្រមាណចំនួន អត្រាប្រាន៉ាឡង់ HIV/STI និងឥរិយាបទប្រឈម ក្នុងចំណោម KPs


Recent size estimates, HIV/STI prevalence and high-risk characteristics among KPs

Key Population Characteristics	Female Entertainment Workers	Men who have Sex with Men	Transgender Women	People who Inject Drugs	People who Use Drugs
Size Estimate (2022)	52,400	86,800	15,900	3,202	22,374
HIV prevalence[18]	4.9%	5.5%	13.5%	10.6%	5.6%
STI prevalence	34%	14.2%	34.6%	5.2%	3.4%
Consistent condom use by type of partner					
During high-risk sex	46%	62.2%	60%	23%	8.6%
Commercial partner	62%	50% (2019)	56% (2019)	73%	59%
Regular partner	17%	52.6%	49%	N/A	N/A

៥. របាយនៃការឆ្លងថ្មីប្រចាំឆ្នាំតាមក្រុមអាយុ ពីឆ្នាំ២០១៧-២០២៥

Increasing proportion of diagnoses among young females < 30 yrs old but young males <30 yrs old proportion is stable and capped around 50%





៦. សង្ខេបកម្មវិធីជាតិបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

PMTCT summary

	2015	2016	2017	2018	2019	2020	2021	2022	2023	2024	2025
Mothers needing PMTCT	1,041	970	909	856	807	753	704	658	621	588	553
Mothers receiving PMTCT	797	720	755	661	586	597	472	528	568	561	544
Option B+: ART started before current pregnancy	720	588	607	507	483	471	389	458	398	373	411
Option B+: ART started > 4 weeks before delivery	0	84	81	103	62	73	44	56	83	116	66
Option B+: ART started < 4 weeks before delivery	48	48	67	51	41	53	39	14	87	72	67
PMTCT coverage	73.77	74.21	83.08	77.19	72.64	79.33	67.03	80.22	91.48	95.47	98.39
MTCT rate at 6 weeks	7.42	7.81	5.9	7.23	8.17	6.88	9.7	6.34	3.99	3.08	2.75
Final transmission rate including breastfeeding period	14.56	15.09	12.14	14.02	15.31	13.33	17.41	12.59	8.81	7.4	6.81

២

ស្ថានភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៦

ក. រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា (១)



- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨
- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨
- គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា

ក. គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ (២)

- **ចក្ខុវិស័យ៖** ធានាថាប្រទេសកម្ពុជាជាប្រទេសមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងធានាថាប្រជាជនកម្ពុជាមានសុខភាពល្អ និងរស់នៅប្រកបដោយសុខុមាលភាព គ្មានការភ័យខ្លាច ដោយសារជំងឺអេដស៍។
- កម្មវត្ថុ៖ ៣
- គោលដៅ៖ ៧
- វិធានការគោលនយោបាយ៖ ៥៣



ក. ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨ (៣)

ចក្ខុវិស័យ៖ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ និងគ្មានការមាក់ងាយ និងរើសអើង

បេសកកម្ម៖ ធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្ន ដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន់ និង មានចីរភាព

គោលដៅ៖ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាព ដែលធានាថាជំងឺអេដស៍លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពីឆ្នាំ២០២៨ តទៅ

គោលបំណង៖ ចំនួន ៤

គោលបំណងទី១
- ផ្តល់ការបង្ការ ព្យាបាល ថែទាំ និងគាំទ្រទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការសម្របសម្រួលល្អ និងប្រើប្រាស់វិធីសាស្ត្រជំរុញការចូលរួមជាពហុវិស័យ

គោលបំណងទី២
- ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាសអំណោយផលឱ្យក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ បានទទួលសេវាមេរោគអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមផ្សេងទៀតប្រកបដោយប្រសិទ្ធភាព

គោលបំណងទី៣
- កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបដោយសហគមន៍ និងកែលម្អការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល

គោលបំណងទី៤
- ធានាចីរភាពសមិទ្ធផលជាតិនៃការឆ្លើយតបនឹងមេរោគអេដស៍ ដោយការបង្កើនការវិនិយោគជាតិ និងការពង្រឹងប្រព័ន្ធប្រទេសឆ្លើយតបនឹងមេរោគអេដស៍ដោយអភិបាលកិច្ច សម្របសម្រួល និងត្រួតពិនិត្យ

ក. សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៥ (៤)

១- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តត្រូវបន្តជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកានានាដើម្បីបញ្ជ្រាបការយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍និងជំងឺអេដស៍ ការមាក់ងាយ រើសអើង ដោយទាក់ទាញនិងលើកទឹកចិត្តប្រជាជនទូទៅ ជាពិសេសប្រជាជនគន្លឹះមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ថែទាំព្យាបាលឱ្យបានទាន់ពេលវេលា ទូលំទូលាយ និងតាមលទ្ធភាព។

២- គ្រប់រដ្ឋបាលរាជធានី ខេត្តត្រូវគាំទ្រ រៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានចប់សព្វគ្រប់១០០% នាដំណាច់ឆ្នាំ២០២៥។

៣- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវប្រើប្រាស់ថវិកា ៨០លានរៀល ៦០លានរៀល ៤០លានរៀល ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជជូនជារៀងរាល់ឆ្នាំលើការងារអេដស៍ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពខ្ពស់។

៤- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ណែនាំជួយសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញជាដៃគូ មន្ទីរពាក់ព័ន្ធ(ផែនការ ទេសចរណ៍ សុខាភិបាល) និងបេឡាជាតិសន្តិសុខសង្គម ជំរុញប្រជាជនគន្លឹះបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ មានជាអាទិ៍ បុរសរួមភេទជាមួយបុរស(MSM) អ្នកបំរែងភេទ(TG) ស្ត្រីបម្រើក្នុងសេវាកម្សាន្ត(EW) មកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគ និងប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍នានា ព្រមទាំងពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.) ដល់ប្រជាជនគន្លឹះឱ្យបានយ៉ាងឆាប់រហ័សនិងបានទូលំទូលាយ។

៥- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវណែនាំរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់លើកផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងប្រើប្រាស់ថវិកាតាមសារាចរអន្តរក្រសួងលេខ០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ដើម្បីទទួលបាននូវប្រសិទ្ធភាព សក្តិសិទ្ធិភាព និងចីរភាព។

៦- ក្រសួងសុខាភិបាលបន្តពង្រីកសេវាធ្វើតេស្តរកមេរោគអេដស៍ សេវាបង្ការមុនពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PrEP) សេវាបង្ការក្រោយពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PEP) និងលើកទឹកចិត្តការប្រើប្រាស់ស្រោមអនាម័យឱ្យមានប្រសិទ្ធភាពជាប្រចាំដល់ក្រុមគោលដៅ ព្រមទាំងខិតខំទប់ស្កាត់ការឆ្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានប្រសិទ្ធភាពខ្ពស់។

៧- ក្រសួងសុខាភិបាលបន្តពង្រឹង ពង្រីកសេវាថែទាំព្យាបាល អ្នកផ្ទុកមេរោគអេដស៍ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

៨- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តត្រូវផ្តល់របាយការណ៍នៃការអនុវត្តថវិកាឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់។

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥


ប្រធានអង្គប្រជុំ
ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង_ហុយ

ក. លទ្ធផលចម្បងៗនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ (៥)

- កម្ពុជាសម្រេចបានគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ មុនកាលកំណត់សម្រាប់ឆ្នាំ ២០៣០ ក្នុងក្របខ័ណ្ឌការបញ្ចប់អេដស៍ដែលជាការគំរាមកំហែងសុខភាពសាធារណៈ។
- អត្រាឆ្លងថ្មីនៃមេរោគអេដស៍ បានថយចុះពី ១៧០០នាក់ (ឆ្នាំ២០១៧) មកត្រឹម ៩៥៨នាក់ (ឆ្នាំ២០២៥)
- ចំនួនអ្នកស្លាប់ទាក់ទងនឹងមេរោគអេដស៍និងជំងឺអេដស៍មានចំនួន ៩៧៤នាក់ ក្នុងឆ្នាំ២០២៥។
- មានអ្នកផ្ទុកមេរោគអេដស៍កំពុងទទួលការព្យាបាលដោយ ARV ចំនួន ៧២ ៤៤០នាក់ នៅតាមសេវាព្យាបាលជំងឺអេដស៍ចំនួន ៧៤ កន្លែងទូទាំងប្រទេស (ត្រីមាសទី១ ឆ្នាំ២០២៦) ។
- មានអ្នកផ្ទុកមេរោគអេដស៍ចំនួន ៥៥ ១៩៨នាក់ (៧៦,១៨%) នៃអ្នកមកទទួលសេវាព្យាបាលថែទាំដែលបានទទួលបណ្ណាមូលនិធិសមធម៌សុខាភិបាល (ម.ស.ស.) នៅតាមមូលដ្ឋានសុខាភិបាលទូទាំង២៥ រាជធានី ខេត្ត (ត្រីមាសទី១ ឆ្នាំ២០២៦)។

ក. រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា (៦)





សម្តេចបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី បានទទួលជួបពិភាក្សាការងារជាមួយលោក Eamonn Murphy, UNAIDS Regional Director for Asia and the Pacific ។ កម្ពុជាសម្រេចបានគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ មុនកាលកំណត់អង្គការសហប្រជាជាតិឆ្នាំ២០៣០ ជាប្រទេសដំបូងគេក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ប្រទេសចំនួន៧នៅទ្វីបអាហ្វ្រិក និង២ទៀតនៅទ្វីបអឺរ៉ុប (ថ្ងៃទី១២ មិថុនា ឆ្នាំ២០២៦)។

ក. រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា (៧)



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុន្នីរ័ត្ន** បានទទួលជួបពិភក្សាការងារជាមួយលោក Eamonn Murphy, UNAIDS Regional Director for Asia and the Pacific ដោយផ្តោតលើចីរភាពនៃការឆ្លើយតបមេរោគអេដស៍នៅកម្ពុជានាពេលអនាគត និងបានបញ្ជាក់សាជាថ្មីថា រាជរដ្ឋាភិបាលកម្ពុជាធានាចីរភាពសមិទ្ធផលនៃការឆ្លើយតបដើម្បីឈានទៅបញ្ចប់អេដស៍ដែលជាការគំរាមកំហែងសុខភាពសាធារណៈ (ថ្ងៃទី១២ មិថុនា ឆ្នាំ២០២៦)។

ក.ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍(៨)





ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង ម៉ូលី** ទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ Vladanka Andreeva, UN Resident Coordinator for Cambodia អមដោយលោកស្រី Patricia Ongpin, Regional Country Director ប្រចាំកម្ពុជា ទ្បាវ ម៉ាទ្បេស្ស៊ី និងវៀតណាម។ កម្ពុជាប្តេជ្ញាធ្វើការជាមួយអង្គការសហប្រជាជាតិ ព្រោះកម្ពុជាមានការជឿជាក់លើប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ពឹងផ្អែកលើធម្មនុញ្ញអង្គការសហប្រជាជាតិ និងជឿទុកចិត្តលើច្បាប់អន្តរជាតិ (ថ្ងៃទី១៨ មីនា ឆ្នាំ២០២៦)។

គោលដៅទី១៖ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍(១)





អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល និង UNAIDS បានពិភាក្សា និងបញ្ជាក់ថាកម្ពុជាកំពុងស្ថិតនៅជួរមុខគេក្នុងការឆ្លើយតបនឹងមេរោគអេដស៍ជាសកល ក្នុងការសម្រេចឱ្យបាននូវគោលដៅ ៩៥-៩៥-៩៥ តាមរយៈការដឹកនាំនយោបាយដ៏រឹងមាំ ការសម្របសម្រួលអន្តរវិស័យ និងគោលនយោបាយបរិយាបន្នដែលមិនមានការរើសអើង (ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៦)។

គោលដៅទី១៖ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍(២)





ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី បានធ្វើជាអធិបតី និងដឹកនាំកិច្ចប្រជុំស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ នៅសណ្ឋាគារឯករាជ្យ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦)។

គោលដៅទី១៖ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍(៣)





ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** បានធ្វើជាអធិបតី និងដឹកនាំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងតាមដានការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨ និងក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីតាមដានសមិទ្ធផលការងារសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ២០២៦ (ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦)។


គោលដៅទី១៖ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍(៤)





- **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំគណៈប្រតិភូអន្តរក្រសួង និងដៃគូពាក់ព័ន្ធចុះទៅខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យ ពិនិត្យស្វែងយល់ពីស្ថានភាពរាលដាលមេរោគអេដស៍ និងការឆ្លើយតបជាពហុវិស័យ ដើម្បីពន្លឿនការសម្រេចបានគោលដៅបញ្ចប់អេដស៍នាឆ្នាំ២០២៨ (ថ្ងៃទី២៧-២៩ ខែមេសា ឆ្នាំ ២០២៦)

សារាចរណែនាំស្តីពីការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% (៥)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២០ សរ

សារាចរ
ស្តីពី
ការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០ភាគរយ

១- បន្តផ្សព្វផ្សាយអំពីប្រសិទ្ធភាពនៃការប្រើស្រោមអនាម័យ១០០% ក្នុងការទប់ស្កាត់ការចម្លងមេរោគអេដស៍ពីដៃគូរួមភេទ។

២- បន្តអប់រំផ្សព្វផ្សាយដល់ឃុវជននិងសាធារណជនជាទូទៅឱ្យយល់ច្បាស់អំពីហានិភ័យនៃមេរោគអេដស៍បញ្ជាក់ជាថ្មីថាមេរោគអេដស៍អាចផ្ទុះពីករាលដាលឡើងវិញក្នុងទ្រង់ទ្រាយធំ ដែលកម្ពុជាពិបាកនឹងគ្រប់គ្រង ប្រសិនបើគ្មានវិធានការបង្ការការពារយ៉ាងហ្មត់ចត់ទេនោះ។

៣- ជំរុញបុគ្គលទាំងឡាយដែលសង្ស័យថាមានផ្ទុកមេរោគអេដស៍ ត្រូវតែប្រញាប់ទៅធ្វើតេស្តរកមេរោគអេដស៍ជាបន្ទាន់ ដើម្បីទទួលបានសេវាថែទាំព្យាបាលទាន់ពេលវេលា។

៤- ធានាឱ្យមានការរក្សាទុកនិងការចែកចាយស្រោមអនាម័យឱ្យបានទូលំទូលាយនៅតាមទីកន្លែងដែលមានការចាំបាច់នានា ជាពិសេសនៅក្នុងភូមិសាស្ត្រដែលមានបម្រើសេវាកម្មាន្តទេសចរណ៍ដូចជារង្គសាល បៀរហ្គាឌិន សណ្ឋាគារ ផ្ទះសំណាក់ ឬគ្រប់ទីកន្លែងដែលសង្ស័យថាអាចមានការរួមភេទ ជាដើម។

៥- មិនត្រូវយកស្រោមអនាម័យធ្វើជាកម្មវត្ថុនៃការដោក់បន្ទុកឡើយ លើកលែងតែការប្រើស្រោមអនាម័យក្នុងការប្រព្រឹត្តបទល្មើស។

ទទួលបានសារាចរនេះ: ទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ១៤ រោច ខែចិត្តសីហ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២៥

ដោយអាជ្ញាធរ
សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ឧត្តមក្រឡាសារមហាបវរធិបតីនាយករដ្ឋមន្ត្រី




- **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ម្ងលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទឹកចិត្តម្ចាស់គ្រឹស្ថានសេវាកម្សាន្តសប្បាយចូលរួមអនុវត្តលិខិតលេខ២០សរ សារាចរស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០ភាគរយ។

សារាចរាជរដ្ឋាភិបាល លេខ២០ សរ៖ ជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% (៦)

ក្រសួង ស្ថាប័ន	លេខ	កាលបរិច្ឆេទ
ក្រសួងមហាផ្ទៃ	០២១ សណន	២៧ មេសា ២០២៦
ក្រសួងទេសចរណ៍	០០១សណន	១២ មករា ២០២៦
ក្រសួងធម្មការ និងសាសនា	០៤/២៦ក.ធ.ស/សណ.ន.	១៣ កុម្ភៈ ២០២៦
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	០០២ ស.អ.យ.	២១ មេសា ២០២៦
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	០៤៥/២៦ក.ប/ស.ណ.ន.	២២ ឧសភា ២០២៦
ក្រសួងព័ត៌មាន	០០១ សនណ. ពម	៣០ មេសា ២០២៦
រាជធានីភ្នំពេញ (ក្រុមការងារ)	០២៨/សសរ.អ	១១ កុម្ភៈ ២០២៦
ខេត្តពោធិ៍សាត់	៧៤/២៦សសរ.ខពស	១៨ កក្កដា ២០២៥
ខេត្តបន្ទាយមានជ័យ	០៥៦/២៦សសរ	២៣ មេសា ២០២៦

ក្រសួង ស្ថាប័នជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចន្លួន២៨ បានផ្សព្វផ្សាយពីហានិភ័យ មេរោគអេដស៍ ជំងឺអេដស៍ ការប្រើប្រាស់ស្រោមអនាម័យ ការលុបបំបាត់ការមាក់ងាយ និងការរើសអើង

លិខិតលេខ២១ សជណ.កប របស់គណៈរដ្ឋមន្ត្រី ស្តីពីករណីវិធានការជំរុញប្រសិទ្ធភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (៧)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ២១...សជណ.កប

ថ្ងៃព្រហស្បតិ៍ ៩កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មករា ឆ្នាំ២០២៦

គោរពជូន
ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី
ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រីក្រៅក្រសួង ស្ថាប័ន អតិបាលនៃគណៈអតិបាលរាជធានី ខេត្ត

កម្មវត្ថុ ៖ ករណីវិធានការជំរុញប្រសិទ្ធភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។
យោង ៖ លទ្ធផលនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ៨កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមគោរពជម្រាបជូន ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចឯកភាពជាគោលការណ៍លើសំណូមពររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ ដែលបានលើកឡើងក្នុងរបាយការណ៍វឌ្ឍនភាពស្តីពីការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ឆ្នាំ២០២៤ ដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យលទ្ធភាពរកាជំរើសជំលក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដែលបានលើកផែនការសកម្មភាពនិងសូចនាករឲ្យស់លាស់ ស្របតាមការកិច្ចដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃគោលនយោបាយជាតិបញ្ចប់អេដស៍ និងបីរគាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ មេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ង្វៀ ឌីសុត

ចម្លងជូន:
- ឧត្តមក្រឡាបញ្ជីនៃអគ្គនាយករដ្ឋមន្ត្រី



គោលដៅទី២៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ (១)





- ឯកឧត្តមសាស្ត្រាចារ្យ **ឈាង ង៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានបញ្ជាក់អំពីការបន្តប្តេជ្ញាចិត្តរបស់ក្រសួងសុខាភិបាល ក្នុងការបញ្ចប់ជំងឺអេដស៍ ជាការគំរាមកំហែងដល់សុខភាពសាធារណៈនៅឆ្នាំ ២០៣០ តាមរយៈការពង្រឹងការធ្វើសមាហរណកម្មសេវាបង្ការ ធ្វើតេស្ត និងព្យាបាលអេដស៍ ទៅក្នុងប្រព័ន្ធសុខាភិបាល ការពង្រីកសេវា PrEP ការធ្វើតេស្តដោយខ្លួនឯង ការពង្រឹងប្រព័ន្ធសហគមន៍ និងការបង្កើននិរន្តរភាពហិរញ្ញប្បទានសម្រាប់កម្មវិធីអេដស៍នៅកម្ពុជា។

គោលដៅទី២៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ (២)

- សេវា HIVST សម្រាប់ KPs មានការកើនទ្វេដង និងត្រូវបានពង្រឹង។ HIVST បានពង្រីកបន្ថែមរហូតដល់ ៣៩ កន្លែង ART ក្នុង១៦ រាជធានី ខេត្ត។
- សេវា PrEP បានពង្រីកពី៤៥ ទៅ៦២ កន្លែង ចន្លោះពីខែមករា ឆ្នាំ២០២៥ ដល់ខែមីនា ឆ្នាំ ២០២៦។
- NCHADS (MOH) បានរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់កម្មវិធីបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងកាមរោគ ក្នុងវិស័យសុខាភិបាល ឆ្នាំ២០២៦-២០៣០។
- បានធ្វើបច្ចុប្បន្នភាពការប៉ាន់ប្រមាណអ្នកផ្ទុកមេរោគអេដស៍ សម្រាប់ថ្នាក់ជាតិ ឆ្នាំ២០២៥ (HIV Estimates for National level 2025)។
- NCHADS (MOH) បានរៀបចំគោលការណ៍ណែនាំសម្រាប់អនុវត្តការផ្តល់អន្តរាគមន៍ រួមបញ្ចូលគ្នាមេរោគអេដស៍/ជំងឺអេដស៍ ជាមួយសុខភាពផ្លូវចិត្ត និងគ្រឿងញៀន។

សកម្មភាពដែលបានអនុវត្តក្នុងត្រីមាសទី១ ឆ្នាំ ២០២៦ (៣)









- ក្រសួងទេសចរណ៍បានរៀបចំព្រឹត្តិការណ៍បុណ្យទន្លេលើកទី១០ ដោយមានការផ្សព្វផ្សាយការយល់ដឹងពីមេរោគអេដស៍និងជំងឺអេដស៍ និងចែកស្រោមអនាម័យដើម្បីបង្ការការឆ្លងមេរោគអេដស៍ដល់សាធារណជននៅខេត្តក្រចេះ ថ្ងៃទី២៧-២៩ មីនា ២០២៦។

កម្ពុជាសម្រេចបាន ៩៥-១០០-៩៨ នៃគោលដៅ ៩៥-៩៥-៩៥ (៤)

ល្បាក់នៃការធ្វើតេស្តមេរោគអេដស៍ និងការព្យាបាលនៅកម្ពុជា ឆ្នាំ២០២៣-២០២៥
HIV testing and treatment cascade, Cambodia, 2023-2025




គោលដៅទី២៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ (៥)




Source: National Prevention Database (NPD), NCHADS

គោលដៅទី២៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ (៦)


លទ្ធផលរបស់កម្ពុជាក្នុងការបង្ការ និងការព្យាបាល






Source: National Prevention Database (NPD), NCHADS

គោលដៅទី៣៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីថែទាំ និងព្យាបាល (១)



គោលដៅទី៤៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម (១)

- រាជរដ្ឋាភិបាលចេញពីប្រកាស លេខ០២ ប្រកព សម្រេចផ្តល់ជម្រើស២ ៖
  - បុគ្គលបម្រើការក្នុងសេវាកម្មាន្តទេសចរណ៍ក្រីក្រ អាចចុះឈ្មោះសុំសម្គាសន៍ដើម្បីទទួលបាន**បណ្ណសមធម៌** តាមប្រកាសក្រសួងផែនការ លេខ ០១១៩ ផក
  - បុគ្គលក្រៅពីនោះនឹងត្រូវចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល (**បណ្ណ មស.ស.**) តាមប្រកាសអន្តរក្រសួងលេខ ៣៥៩ សហវ.ប្រក អកគ
- អ.ជ.ប.ជ.អ. និយាមប្រតិបត្តិស្តីពីការចុះបញ្ជី-ការផ្តល់ និងការប្រើប្រាស់បណ្ណមូលនិធិសមធម៌សុខាភិបាល (**បណ្ណ មស.ស.**) ដល់បុគ្គលបម្រើក្នុងសេវាកម្មាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
  - គោលដៅ៖ ចុះបញ្ជីផ្តល់បណ្ណម.ស.ស. ដល់ប្រជាជនគន្លឹះដែលជាបុគ្គលបម្រើការក្នុងសេវាកម្មាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទាំងស្ត្រី បុរសរួមភេទ ជាមួយបុរស និងអ្នកបំប្លែងភេទ ឱ្យបាន **៥០% នៅដំណាច់ឆ្នាំ២០២៥**។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០២ ប្រកព

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
ការផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល
សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្មាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្នុងបរិការណ៍នៃសុខសន្តិភាព និងស្ថេរភាពនយោបាយ, រាជរដ្ឋាភិបាលតែងតែគិតគូរយ៉ាងមធ្យ័តអំពីសុខុមាលភាពរបស់ប្រជាជនកម្ពុជាគ្រប់រូប ដោយឈរលើគោលនយោបាយ "មិនបោះបង់ពលរដ្ឋណាម្នាក់" ឡើយ។ ជាមួយនឹងការគិតគូរនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវអន្តរាគមន៍គាំពារសង្គមនានា ក្នុងគោលបំណងជានាឱ្យបាននូវសន្តិសុខប្រាក់ចំណូល កាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ពេលនេះ រាជរដ្ឋាភិបាលសម្រេចផ្តល់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្មាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសស្ត្រីដែលបម្រើការនៅតាមង្គេសាល, ទីស្នាក់តែក, ខារ៉ាអូខេ, បៀរហ្គាឌិន, កន្លែងម៉ាស្សា និងស្ប៉ា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលរដ្ឋនឹងរាប់រងនូវចំណាយទាំងស្រុង។

ទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវរៀបចំបញ្ជីឈ្មោះបុគ្គលបម្រើការក្នុងសេវាកម្មាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ដើម្បីបញ្ជូនទៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ ដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ មុននឹងស្នើទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដើម្បីចុះបញ្ជីឱ្យពួកគាត់អាចទៅទទួលយកអត្ថប្រយោជន៍ក្រោមកញ្ចប់មូលនិធិសមធម៌សុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ នៅទូទាំងប្រទេស ដោយឥតបង់ថ្លៃ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible]
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ[illegible]

គោលដៅទី៤៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម (២)

វឌ្ឍនភាពនៃការថែទាំ និងព្យាបាលជំងឺអេដស៍ និងការទទួលបានបណ្ណ ម.ស.ស.

- ត្រីមាសទី១ ឆ្នាំ២០២៦ មានអ្នកបានទទួលបណ្ណមូលនិធិសមធម៌សុខាភិបាលចំនួន **៥៥ ១៩៨នាក់** ក្នែអ្នកផ្ទុកមេរោគអេដស៍សកម្មកំពុងទទួល ART **៧២ ៤៤០នាក់** គឺស្មើប្រមាណ **៧៦,១៨%** (NCHADS)។
- ក្នុងរយៈពេល៣ខែដើមឆ្នាំ២០២៦ តាមរយៈការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារជនមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ក្នុងគ្រួសារមានបណ្ណសមធម៌ចំនួន៦៥១៦នាក់ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ។ រាជរដ្ឋាភិបាលបានផ្តល់សាច់ប្រាក់ប្រមាណ**១១៨៦លានរៀល** (MoEF)។

បញ្ជីឈ្មោះរាជធានី-ខេត្ត ស្នើសុំបណ្ណ ម.ស.ស. ផ្នែកសេវាកម្មាន្ត

គិតត្រឹមថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦

ល.រ	រាជធានី/ខេត្ត	ចំនួនសហគ្រាសេវាកម្មាន្តតាមរាជធានី/ខេត្ត	ចំនួនថ្ងៃបំណ្ឈ		ផ្សេងៗ
			ចំនួនសរុប	ចំនួនស្រី	
១	ដង្កោ	១៦	២៩	១៩	
២	ច្បារអំពៅ	១៦	២៨	២	
៣	ចូលគោក	៣៦	១១៦	៧៨	
៤	ជ្រុងពេញ	៣១	២១៥	១៨១	
៥	ចឹងកេងកង	៨	១៥៣	១០២	
៦	៧មករា	១១	៤៩	៤១	
៧	មានជ័យ	៥	១៨	១៨	
៨	ចំការមន	១៨	៥៥	៣២	
៩	ពោធិ៍សែនជ័យ	៣៨	២៩៥	៨៨	
១០	ឫស្សីកែវ	១២	៣៨	៣៨	
១១	ព្រៃឈរចង្វារ	១០	១៨	១៧	
១២	សែនសុខ	៥	៤០	៤០	
១៣	កំបូល	៨	២២	១៣	
	សរុប(០១)	២០៦	១០៧២	៦៥៧	
១	ខេត្តពោធិ៍សាត់	២០	១៥៦	១០៨	
២	ខេត្តស្វាយរៀង	៨២	៧៥៦	៥០៩	
៣	ខេត្តបន្ទាយមានជ័យ	១៨	២៧៨	១៦០	
៤	ខេត្តកំពត	៧៦	៣៣២	២៧៦	
៥	ខេត្តកំពង់ចាម	១១៨	៩២៣	៧០៥	
៦	ខេត្តឧត្តរមានជ័យ	៨៣	៣១៨	២៦៧	
៧	ខេត្តក្រចេះ	២២	១៨៦	១៣២	
៨	ខេត្តកំពង់ស្ពឺ	៨	៨៥	៥៧	
៩	ខេត្តកំពង់ធំ	២៥	២៨០	១៧៦	
	សរុប(០២)	៤០៤	៣២២៦	២៣៨៦	
	ចំនួនសរុប (០១+០២)	៦១០	៤២៩៨	៣០៤៣	


គោលដៅទី៥៖ ការបញ្ចប់ការរើសអើង និងការមាក់ងាយ(១)

- **ផែនការសកម្មភាពជាតិ** ដើម្បីដោះស្រាយការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ បានអនុវត្តដោយវិស័យទាំង៣ (សុខាភិបាល អប់រំ និងសហគមន៍)។
- **គោលការណ៍ណែនាំ**សម្រាប់អនុវត្តយន្តការរាយការណ៍ និងការឆ្លើយតបចំពោះការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍នៅកម្ពុជា។
- បានផ្សព្វផ្សាយឯកសារទាក់ទងនឹងការលុបបំបាត់ការមាក់ងាយ និងការរើសអើងលើក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ ដល់អ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិ និងក្រោមជាតិ និងដាក់ឱ្យអនុវត្ត។
- បានរៀបចំកិច្ចប្រជុំអ្នកពាក់ព័ន្ធដើម្បីពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្ត ១)**ផែនការសកម្មភាពជាតិ និង គោលការណ៍ណែនាំ** ដើម្បីដោះស្រាយការមាក់ងាយនិងការរើសអើង។
- សេវាមេត្រីភាព KP Friendly Service សម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ ដែលអនុវត្តដោយវិស័យសុខាភិបាលត្រូវបានពង្រឹង និងពង្រីកបានរហូតដល់៨កន្លែង នៅក្នុង៨ខេត្ត។
- ក្រសួងអប់រំយុវជន និងកីឡា បានបញ្ចូលការអប់រំពីការលុបបំបាត់ការរើសអើង និងមាក់ងាយក្នុងមុខវិជ្ជាសិក្សាសុខភាពបន្តពូជគ្រប់ជ្រុងជ្រោយ។

គោលដៅទី៥៖ បញ្ចប់ការរើសអើង និងមាក់ងាយ (១)

HACC Network of NGOs on Health
Health Action Coordinating Committee

HIV Education & Prevention		Download
ទទួលបានអប់រំ HIV 3ខែ	47%	47%
បានធ្វើតេស្ត & ប្រឹក្សា HIV 6ខែ	48%	48%
កំពុងប្រើ PrEP	39.8%	39.8%
បទពិសោធ chemsex	35%	35%
Care & Treatment		Download
PLHIV ទទួល ARV 3-6ខែ	95%	95%
PLHIV VL Suppressed	94%	94%
PLHIV មិនយល់ U=U	38.6%	38.6%
Social Protection		Download
មានភាតសង្គម	53%	53%
បានប្រើសេវាសុខភាព	57%	57%
ពេញចិត្តសេវាសុខភាព	80%	80%
GBV		Download
បទពិសោធ GBV 3ខែ	20%	20%
យល់ច្បាប់អេដស៍	42%	42%
យល់ GBV human rights	45%	45%
Stigma & Discrimination		Download
បទពិសោធ HIV-S&D 6ខែ	23%	23%
គាំទ្រទីតំណាងជាតិ	32%	32%
គាំទ្រទីតំណាងក្រោមជាតិ	33%	33%
Mental Health		Download
ដឹងថែទាំសុខភាពផ្លូវចិត្ត	67%	67%
គ្មានហានិភ័យចិត្ត 2សប្តាហ៍	30%	30%
បានប្រឹក្សាជាមួយអ្នកជំនាញ		3.9%




ទិន្នន័យ CLM ត្រូវបានប្រើប្រាស់ជាវេទិកាផ្សព្វផ្សាយ និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធក្នុងខេត្តគោលដៅទាំង១២ខេត្តរបស់វេទិកាហ្វុនប៉ាម ដើម្បីជំរុញភាពល្អប្រសើរឡើងនូវកម្មវិធីអេដស៍ និងសេវាពាក់ព័ន្ធ

ការអនុវត្ត CLM ខែមករា ដល់ ខែឧសភា ឆ្នាំ២០២៦ (៣)

ការអនុវត្តយន្តរាយការណ៍ និងឆ្លើយបត S&D ពាក់ព័ន្ធនឹងជំងឺអេដស៍ (២)

HACC Network of NGOs on Health
Health Action Coordinating Committee

- វេទិកាផ្សព្វផ្សាយអំពីយន្តការរាយការណ៍ និងឆ្លើយតបករណីមាក់ងាយ រើសអើង និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលពាក់ព័ន្ធនឹងមេរោគអេដស៍ ចំនួន៤ដង ដល់សហគមន៍ក្នុងខេត្តគោលដៅទាំង៤ រួមមាន បាត់ដំបង សៀមរាប បន្ទាយមានជ័យ និងរាជធានភ្នំពេញ សរុបសហគមន៍ចូលរួមចំនួន១៨៣នាក់
- បានរៀបចំវេទិកាផ្សព្វផ្សាយអំពីការលើកកម្ពស់ការយល់ដឹងអំពីការមាក់ងាយ រើសអើង អំពើហិង្សាទាក់ទងនឹងយេនឌ័រ សិទ្ធិអតិថិជន កិច្ចគាំពារសង្គម ដល់សហគមន៍ PLHIV/KP ក្នុង១២ខេត្ត





Date	Community	Location	Case	Contacted	Solved	Need legal support
21-Apr-26	PLHIV	SRP	No answer phone	No	N/A	N/A
21-Apr-26	TG	SRP	Use "A Khteoy and Postive AIDS"	Yes	No	On the process of log Camplaint
21-Apr-26	TG	SRP	No answer phone	No	N/A	N/A
2-Mar-26	MSM	BTB	No answer phone	No	N/A	N/A

គោលដៅទី៦៖ ចលនាធនធាន (១)

- មូលនិធិសកល(Global Fund) ជាសាច់ប្រាក់ចំនួន ៤១,៦លានដុល្លារសម្រាប់រយៈពេលបីឆ្នាំ (២០២៤-២០២៦)។
- ប្រទេសផ្តល់ជំនួយដូចជាសហរដ្ឋអាម៉េរិក អូស្ត្រាលី បារាំង និងប្រព័ន្ធអង្គការសហប្រជាជាតិក៏បានផ្តល់ថវិកា ២៤,២ លានដុល្លារ សម្រាប់រយៈពេលបីឆ្នាំផងដែរ។
- រាជរដ្ឋាភិបាលផ្តល់ថវិកាប្រមាណជា ១៥លានដុល្លារទិញថ្នាំព្យាបាល(ARV) និង ១៣,២លានដុល្លារសម្រាប់ ឧបករណ៍សុខាភិបាល និងបុគ្គលិកជាប់កិច្ចសន្យា សម្រាប់រយៈពេល៣ឆ្នាំដូចខាងលើ។
- រាជរដ្ឋាភិបាលផ្តល់ថវិកាសម្រាប់អត្ថប្រយោជន៍គាំពារសង្គម កម្រៃសេវានៃការព្យាបាលអ្នកជំងឺអេដស៍ បញ្ជោបការងារ អេដស៍ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ប្រមាណ ២,៦លានដុល្លារក្នុងមួយឆ្នាំចាប់ពីឆ្នាំ២០២៣។
- រាជរដ្ឋាភិបាលវិភាជន៍ថវិកាសម្រាប់រាជធានី ខេត្តចំនួន៨០លាន ៦០លាន និង៤០លានរៀលក្នុងមួយឆ្នាំ ដើម្បីរៀបចំ បង្កើត និងដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក និងឃុំ សង្កាត់ ស្មើនឹង ៣៥៥.០០០ដុល្លារ។
- យើងកំពុងរៀបចំគម្រោងសំណើមូលនិធិសកលសម្រាប់ការងារអេដស៍ របេង និងគ្រុនចាញ់ ជុំទី៨ (CG8, ២០២៧-២០២៩) ហើយរាជរដ្ឋាភិបាលកំពុងពិចារណាទំហំថវិកាបដិភាគ (Co-Financing) សម្រាប់គម្រោងនេះ។

ការប្តេជ្ញាចិត្តក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍

ប្រភពថវិកាសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍

HIV funding source	2022	2023	2024	2025	2026
RGC (Co-Financing)	4,900.0	6,500.0	6,600.0	6,600.0	6,600.0
RGC (For Sub-National level)	80.0	245.0	345.0	345.0	345.0
RGC (Commune/Sangkat)	35.3	39.6	397.7	586.9	
Global Fund	1,400.0	1,200.4	13,800.0	13,800.0	13,800.0
UNAIDS	1,591.8	1,354.0	1,302.0	1,202.0	1,102.0
USAID	700.0	6,530.0	5,877.0	5,289.3	4,760.3
AHF	2,052.4	2,157.8	2,199.4	2,243.1	2,289.0
France	250.4	577.0	1,283.0	330.0	300.0
Other	29.9	19.6	-	-	-
Total	11,039.8	18,623.4	31,804.1	30,396.3	29,196.3

ផែនការសកម្មភាពថវិកាបានអនុវត្តការឆ្លើយតបអេដស៍ ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន និងថវិកា	ឆ្នាំ២០២៥	ឆ្នាំ២០២៦ (ត្រីមាសទី១)
មានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍	២៥/២៨	៣៣
មានផែនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍	២០	២៥
មានផែនការសកម្មភាព ថវិកាឆ្លើយតបអេដស៍ និង បានទទួលការអនុម័តថវិកាពីក្រសួងសេដ្ឋកិច្ច	១៥	១៣
បានប្រជុំផ្សព្វផ្សាយការងារអេដស៍	២៥	២៨
បានអនុវត្តសកម្មភាពឆ្លើយតបអេដស៍ និងបានចំណាយថវិកា	១៨	២៣
បានផ្ញើរបាយការណ៍មក NAA	២៨	២៨

ផែនការសកម្មភាពថវិកាបានអនុវត្តការឆ្លើយតបអេដស៍នៅថ្នាក់ក្រោមជាតិ

រាជធានី ខេត្ត និងថវិកា	%ថវិកាចំណាយឆ្នាំ ២០២៤	%ថវិកាចំណាយឆ្នាំ ២០២៥	%ថវិកាចំណាយឆ្នាំ ២០២៦
ខេត្តបានទទួលថវិកា៨០លានរៀល (៤ រាជធានី ខេត្ត)	79%-100%	100%	3% - 59%
ខេត្តបានទទួលថវិកា៦០លានរៀល (១១ ខេត្ត)	20% - 54% (2 ខេត្ត)	0% (កណ្តាល)	0% (6 ខេត្ត)
	87% - 100% (9 ខេត្ត)	90% - 100% (10 ខេត្ត)	8%-47% (5 ខេត្ត)
ខេត្តបានទទួលថវិកា៤០លានរៀល (១0 ខេត្ត)	0% (កំពត ស្វាយរៀង)	0% (កំពត)	0% (9 ខេត្ត)
	16%-55% (3 ខេត្ត)	17%-25% (3 ខេត្ត)	3%-10% (២ខេត្ត)
	73% - 100% (5 ខេត្ត)	61%-100% (6ខេត្ត))	

ថវិកាបានចំណាយសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ថ្នាក់ក្រោមជាតិ ២០២៥

ខេត្ត	ឃុំ សង្កាត់បានបណ្តុះបណ្តាល	ឃុំ សង្កាត់មានផែនការថវិកាសកម្មភាពអេដស៍ ២០២៥	សរុបថវិកាក្នុងគម្រោង (រៀល)
បាត់ដំបង	23	18	288,398,000
បន្ទាយមានជ័យ	39	12	82,058,000
សៀមរាប	26	13	47,870,000
ភ្នំពេញ	20	62	326,211,888
តាកែវ	14	11	64,142,000
កណ្តាល	14	29	103,230,000
កំពង់ស្ពឺ	8	8	136,639,500
ព្រៃវែង	14	117	700,511,000
កំពង់ចាម	12	4	75,668,000
ព្រះសីហនុ	5	17	257,250,000
ប៉ៃលិន	8	7	82,826,000
ពោធិ៍សាត់	14	9	38,774,000
កំពង់ឆ្នាំង	៤	៨	៤២,000,000
ត្បូងឃ្មុំ	៧	៣	៧៤,000,000
កំពង់ធំ	១២	៦	២៨,០១០,000
សរុប	220	324	2,347,588,388 ៛ ~ 587,000$


ថវិកាសមាហរណកម្មការងារអេដស៍ក្នុង CIP/CDP ឆ្នាំ២០២៥ និងឆ្នាំ២០២៦

២០២៥			២០២៦		
ឃុំ សង្កាត់បានបណ្តុះបណ្តាល	ឃុំ សង្កាត់មានផែនការសកម្មភាពថវិកាអេដស៍	សរុបថវិកាក្នុងគម្រោង (រៀល)	ឃុំ សង្កាត់បានបណ្តុះបណ្តាល	ឃុំ សង្កាត់មានផែនការថវិកាសកម្មភាពអេដស៍ ២០២៥	សរុបថវិកាក្នុងគម្រោង (រៀល)
២២០	៣២៤	២ ៣៤៧ ៥៨៨ ៣៨៨	២៣៨	៥១៣	២៧៨ ៥០៥ ២០០

ទិន្នន័យឆ្នាំ២០២៦ ប្រមូលបាននៅ ខែមីនា ឆ្នាំ២០២៦

សរុបផែនការថវិកា ឆ្នាំ២០២៥ និង២០២៦ មាន ៥ ១៣៣ ០៩៣ ៥៨៨ ៛

ក្រុមការងារផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទាំង៥ក្រុម (ត)



- បានរៀបចំនិយាមប្រតិបត្តិស្តីពីការឆ្លើយតបមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ ដោយផ្តោតលើមគ្គុទ្ទេសភាព/ភាពជាម្ចាស់ ភាពជាដៃគូ និងការវិនិយោគ។



ក្រុមការងារចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

- ធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវចីរភាពនៃការឆ្លើយតបមេរោគអេដស៍នៅប្រទេសកម្ពុជា (Sustainability Roadmap) បូករួមការណែនាំស្តីពីចីរភាពនៃការឆ្លើយតបមេរោគអេដស៍របស់ពិភពលោក"Global Guidance") មាន៥ចំណុចចម្បងៈ

  ១) ពង្រឹងភាពជាអ្នកដឹកនាំ

  ២) ពង្រឹងរចនាសម្ព័ន្ធ

  ៣) ចលនាប្រកពធនធាន

  ៤) ពង្រឹង ពង្រីកសេវាបង្ការ ថែទាំ និងព្យាបាល

  ៥) បង្កបរិយាកាសគាំទ្រ

- បានធ្វើការប៉ាន់ប្រមាណចំណាយសម្រាប់ផែនទីបង្ហាញផ្លូវចីរភាពនៃការឆ្លើយតបមេរោគអេដស៍នៅប្រទេសកម្ពុជា (Costing Sustainability Roadmap)

៣

បញ្ហាប្រឈម

បញ្ហាប្រឈម (១)

- ករណីឆ្លងថ្មីនៃមេរោគអេដស៍ស្ថិតក្នុងក្រុមយុវវ័យដែលមានអាយុពី១៥ទៅ២៤ឆ្នាំ មាននិន្នាការកើនឡើង។ ក្រុមអាយុ២៥-៣៤ឆ្នាំ ក៏មានការប្រឈមខ្ពស់ដែរ។
- ក្រុមប្រជាជនគន្លឹះ ជាពិសេសក្រុមយុវវ័យបុរសរួមភេទជាមួយបុរស(អាយុ១៥-២៤ឆ្នាំ) ជាមុខសញ្ញាងាយរងគ្រោះខ្ពស់ព្រោះពួកគេពុំបានទទួលការបញ្ជ្រាបការយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍និងជំងឺអេដស៍ (Chemsex)។
- អត្រាប្រើរ៉ាឡង់ជំងឺកាមរោគក្នុងចំណោមក្រុមប្រជាជនគន្លឹះមានកម្រិតខ្ពស់ ឯការប្រើប្រាស់ស្រោមអនាម័យមានកម្រិតប្រមាណ៥០% ប៉ុណ្ណោះ។
- អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូន (៦,៨១) នៅមិនទាន់សម្រេចគោលដៅនៅឡើយ។
- ថវិកាជំនួយពីខាងក្រៅសម្រាប់កម្មវិធីអេដស៍មានការថយចុះបានធ្វើឱ្យការអនុវត្តសកម្មភាពដោយអង្គការសង្គមស៊ីវិលលើការបង្ការមានរឆ្ងាក់ចុះនិងមិនបានគ្របដណ្តប់គោលដៅងាយរងគ្រោះដូចជា៖ ក្រុមយុវវ័យបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ និងក្រុមប្រើប្រាស់និងចាក់គ្រឿងញៀនឱ្យបានទូលំទូលាយ។

បញ្ហាប្រឈម (២)

- ការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ធ្វើបានតែនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដោយឡែកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ពុំទាន់ដំណើរការបានទាំងស្រុងនៅឡើយ។
- ការអនុវត្តថវិការដ្ឋគាំទ្រការប្រយុទ្ធនឹងមេរោគអេដស៍ នៅរដ្ឋបាលខេត្តមួយចំនួនមានការយឺតយ៉ាវ។ ការសម្របសម្រួល និងភាពជាដៃគូក្នុងការអនុវត្តផែនការសកម្មភាពផ្តោតលើលទ្ធផល (ផែនការសមិទ្ធកម្ម) របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ នៅមានកម្រិត។
- ការធ្វើសមាហរណកម្មការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាលជាតិនៅមិនទាន់ធ្វើបានទាំងស្រុង ពិសេសការអនុវត្តលិខិតលេខ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

៤

ទិសដៅអនុវត្តបន្ត

ទិសដៅការងារបន្ត (១)

- ពង្រឹងនិងពង្រីកការអប់រំផ្សព្វផ្សាយអំពីការយល់ដឹងពីមេរោគអេដស៍ និងជំងឺអេដស៍ ការបង្ការព្យាបាលជំងឺកាមរោគ ការប្រើប្រាស់ស្រោមអនាម័យឱ្យបានទូលំទូលាយក្រុមប្រជាជនគន្លឹះ ជាពិសេសក្រុមយុវវ័យ បុរសរួមភេទជាមួយបុរស(អាយុ១៥-២៤ឆ្នាំ)។
- ពិនិត្យលទ្ធភាពបង្កើនថវិកាសម្រាប់កម្មវិធីអេដស៍ដែលអនុវត្តដោយអង្គការសង្គមស៊ីវិលដើម្បីបង្កើនការគ្របដណ្តប់ក្រុមគោលដៅងាយរងគ្រោះដូចជា៖ ក្រុមយុវវ័យ បុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ និងក្រុមប្រើប្រាស់និងចាក់គ្រឿងញៀនឱ្យបានទូលំទូលាយ។
- ពង្រីកការប្រើប្រាស់កម្មវិធីដែលមានស្រាប់ក្នុងប្រព័ន្ធគាំពារសង្គមដើម្បីជំរុញការធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត។
- ជំរុញការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានពេញលេញ។

ទិសដៅការងារបន្ត (២)

- ដំរុញការធ្វើសមាហរណកម្មការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល ពិសេសការអនុវត្តលិខិតលេខ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។
- ដំរុញគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ត្រូវពង្រឹងការរៀបចំផែនការរួមឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសម្របសម្រួលការប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព។
- ពង្រឹងកិច្ចសហការសម្របសម្រួលអ្នកពាក់ព័ន្ធនៅរដ្ឋបាលខេត្តដើម្បីដំរុញការអនុវត្តថវិកាជាតិក្នុងការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។
- ពង្រឹងភាពជាអ្នកដឹកនាំ ភាពជាម្ចាស់របស់មន្ត្រីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ តាមកាលកំណត់ដោយយកប្រយោជន៍សាធារណៈ និងប្រជាជនជាស្នូលនៃការផ្តល់សេវា។









សូមអរគុណ!







៤

ឧបសម្ព័ន្ធ

ចោយការណ៍ដែលទទួលបាន

ស្ថាប័ន	
ក្រសួង ស្ថប័ន	២៨/៣៣
រាជធានី ខេត្ត	២៥/២៥
អង្គការសង្គមស៊ីវិល	ទទួលបានការស្នើសុំ